ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សំណុំរឿងរដ្ឋប្បវេណីលេខ ២៧១
ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០២០
សាលក្រមរដ្ឋប្បវេណីលេខ: ៨៩ "ច"
ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ៥រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រាំបួនព្រឹក នៅសាលសវនាការ លើសំណុំរឿងរដ្ឋប្បវេណីលេខ ២៧១ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

**-ដើមចោទ ៖**

ឈ្មោះ [redacted] **ពីនិច** ភេទប្រុស អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០០ ៤៣៥០៤ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅ [redacted]

- ដោយមានលោក [redacted] អត្តលេខ២១១៨T ជាមេធាវីតំណាងដោយអណត្តិ [redacted] ។

**-សហចុងចម្លើយ ៖**

១. ឈ្មោះ [redacted] **សិរីរ័ត្ន** ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

- ដោយមានលោក [redacted] អត្តលេខ **១០៣** ជាមេធាវីតំណាងដោយអណត្តិ មានអាសយដ្ឋានការិយាល័យ [redacted] ។

២. ឈ្មោះ [redacted] **ស្រស់** ភេទប្រុស អាយុ ៥២ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ។

៣. ឈ្មោះ [redacted] **ម៉ៅ** ភេទប្រុស អាយុ ៤៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

## I. អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖**

១. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] សិរីរ័ត្ន, ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ សងប្រាក់ជំពាក់ចំនួន **៤០៥.០០០USD (សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** មកឲ្យដើមចោទឈ្មោះ [redacted] ពីនិច ។

២. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] **សិរីរ័ត្ន**, ឈ្មោះ [redacted] **ស្រស់** និងឈ្មោះ [redacted] **ម៉ៅ** បង់សំណងជម្ងឺចិត្ត ចំនួន **១០០០.០០០USD (ដប់ម៉ឺន) ដុល្លារអាមេរិក** មកឲ្យដើមចោទឈ្មោះ [redacted] **ពីឌិច** ។

៣. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] **សិរីរ័ត្ន**, ឈ្មោះ [redacted] **ស្រស់** និងឈ្មោះ [redacted] **ម៉ៅ** បង់ការប្រាក់ចំនួន ០២% (ពីរភាគរយ) ក្នុងមួយខែនៃប្រាក់ដែលជំពាក់នៅសល់ តាមកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចំនួន**៤០៥.០០០ (សែសិបម៉ឺនប្រាំពាន់)** គិតចាប់ពី**ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩** ឲ្យដើមចោទឈ្មោះ [redacted] **ពីឌិច** ។

៤. សុំឲ្យតុលាការអនុវត្តបណ្ដោះអាសន្ន គ្រង់ចំណុចទី១ ។

៥. បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] **សិរីរ័ត្ន**, ឈ្មោះ [redacted] **ស្រស់** និងឈ្មោះ [redacted] **ម៉ៅ** ទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។

## ខ. ដំណើររឿងក្ដី និងចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី

កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ សហចុងចម្លើយឈ្មោះ [redacted] **សិរីរ័ត្ន**, ឈ្មោះ [redacted] **ស្រស់** និងឈ្មោះ [redacted] បានចុះកិច្ចព្រមព្រៀងបញ្ចប់វិវាទជាមួយគ្នាដើមចោទឈ្មោះ [redacted] **ពីឌិច** ដោយក្នុងកិច្ចព្រមព្រៀងនោះសហចុងចម្លើយឯកភាពសងប្រាក់ទៅដើមចោទ ក្នុងទឹកប្រាក់ចំនួន **៦០០.០០០(ហុកសិបម៉ឺន) ដុល្លារអាមេរិក** ដោយមានផ្ដិតមេដៃដោយដើមចោទ និងសហចុងចម្លើយ ព្រមទាំងមានហត្ថលេខារបស់មេធាវីផងដែរ ។ ក្រោយពីចុះកិច្ចព្រមព្រៀងជាមួយគ្នាមក ចុងចម្លើយឈ្មោះ [redacted] **សិរីរ័ត្ន** បានសងប្រាក់ទៅដើមចោទបានតែចំនួន **១៩៥.០០០ (ដប់ប្រាំបួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** ចុងចម្លើយក៏ខកខានសងប្រាក់ទៅដើមចោទរហូតមកដល់សព្វថ្ងៃ ។

ដើមចោទបានទាមទារឲ្យសហចុងចម្លើយសងប្រាក់ដែលនៅសល់ចំនួន ៤០៥.០០០ **(សែសិបម៉ឺនប្រាំពាន់)** គិតចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ដោយមូលហេតុ សហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងបញ្ចប់វិវាទ ។

### ខ.២. អង្គហេតុដែលគ្មានវិវាទ

**១.** ដើមចោទ និងចុងចម្លើយទទួលស្គាល់ថា ពិតជាបានចុះកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ដោយឯកភាពលើទឹកប្រាក់ជាក់ស្ដែងចំនួន **៦០០.០០០ (ហុកសិបម៉ឺន) ដុល្លារអាមេរិក** ពិតប្រាកដមែន ។

**២.** ដើមចោទ និងចុងចម្លើយ ទទួលស្គាល់ថា ចុងចម្លើយឈ្មោះ **សួស សិរីរ័ត្ន** បានសងប្រាក់ទៅដើមចោទ ដោយបានសងជាប្រាក់សុទ្ធផង ផ្ទេរកម្មសិទ្ធលើទ្រព្យសម្បត្តិផង និងសងប្រាក់ប្រចាំខែចំនួន **៥.០០០(ប្រាំពាន់) ដុល្លារអាមេរិក** ក្នុងមួយខែផង សរុបជាទឹកប្រាក់ចំនួន **១៩៥.០០០ (ដប់ប្រាំបួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** ។

### ខ.៣. ចំណុចវិវាទ

១. តើកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ រវាងដើមចោទ និងសហចុងចម្លើយធ្វើឡើងដោយមានវិការៈ ដែរឬទេ ?

២. តើការទាមទារសំណងជម្ងឺចិត្ត និងថ្លៃសេវាផ្សេងៗចំនួន ១០០.០០០(ដប់ម៉ឺន) ដុល្លារអាមេរិក មានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរឬទេ ?

៣. តើការទាមទារឲ្យសហចុងចម្លើយសងនូវការប្រាក់ ចំនួន ០២%(ពីរភាគរយ) ក្នុងមួយខែ នៃប្រាក់ដែលនៅជំពាក់ចំនួន **៤០៥.០០០ (សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** មកឲ្យដើមចោទឈ្មោះ [redacted] **សិរីរ័ត្ន** គិតចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមអស់ មានមូលហេតុត្រឹមត្រូវតាមច្បាប់ ដែរឬទេ?

៤. តើការសុំអនុវត្តសាលក្រមនេះជាបណ្តោះអាសន្នត្រង់ចំណុចទី១ នៃការទាមទារ មានមូលហេតុតាមផ្លូវច្បាប់ ដែរឬទេ?

៥. តើសោហ៊ុយចំណាយលើប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយ មានមូលហេតុតាមផ្លូវច្បាប់ដែរឬទេ?

## គ. អង្គហេតុដែលអះអាងដោយគូភាគី

### គ.១. អង្គហេតុដែលអះអាងដោយដើមចោទ

-លោក [redacted] ជាមេធាវីតំណាងដោយអណត្តិឲ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្លួនសូមរក្សាការទាមទារដូចមានក្នុងពាក្យបណ្តឹងចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ទុកជាបានការដដែល ។ ស្នើសុំកែតម្រូវពាក្យបណ្តឹង ត្រង់កាលបរិច្ឆេទ ពីចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ មកជាក់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ វិញ ។

ខ្លួនសូមថ្លែងការណ៍បន្ថែមថាៈ ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ បានធ្វើការឆបោកកូនក្តីរបស់ខ្លួននូវទឹកប្រាក់ប្រហែលជាងមួយលានដុល្លាអាមេរិច ហើយកូនក្តីរបស់ខ្លួនបានដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានីភ្នំពេញក៏ត្រូវសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការឃាត់ខ្លួន ឈ្មោះ [redacted] សេរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ប៉ុន្តែក្រោយមកភាគីទាំង៣នាក់ បានស្នើសុំធ្វើការចរចារ និងព្រមព្រៀងសងប្រាក់កូនក្តីខ្លួនចំនួន៦០០,០០០USD (ហុកសិបម៉ឺនដុល្លាអាមេរិច) និងបានធ្វើលិខិតព្រមព្រៀងគ្នា ដើម្បីសងប្រាក់មកកូនក្តីរបស់ខ្លួនដែលមានការដឹងឮពីមេធាវី ក្រោយពីឈ្មោះ [redacted] សេរីរ័ត្ន និង បក្សពួកចេញពីពន្ធនាគាររួចហើយ ក៏មិនបានបង់ប្រាក់ទៅតាមការកំណត់មកឲ្យកូនក្តីខ្លួនទេ ដែលនេះជាហេតុធ្វើឲ្យកូនក្តីខ្លួនធ្វើការប្តឹងទាមទារប្រាក់ ។ តាំងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទសំណូមពរ សូមឲ្យលោកចៅក្រមសម្រេច តាមពាក្យបណ្តឹងរបស់កូនក្តីខ្លួន ហើយសុំអនុវត្តជាបណ្តោះអាសន្ននូវប្រាក់ដើមចំនួន ៤០៥,០០០USD (សែសិបម៉ឺនប្រាំពាន់ដុល្លាអាមេរិក) ។ សេចក្តីដូចបានជម្រាបជូនខាងលើសូម លោកចៅក្រម មេត្តាសម្រេចតាមការស្នើសុំរបស់ខ្លួន ដោយក្តីអនុគ្រោះ ។ ខ្លួនសូមបដិសេធត្រង់ការលើកឡើងរបស់មេធាវីចុងចម្លើយ ដែលលើកឡើងថា កិច្ចព្រមព្រៀងខាងលើជាកិច្ចព្រមព្រៀងដែលមានវិការៈ ព្រោះជាកិច្ចព្រមព្រៀងដែលត្រូវបានបង្កើតឡើងក្នុងកាលៈទេសៈមួយដែលឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ ឈ្មោះ [redacted] ម៉ៅ កំពុងជាប់ឃុំនៅពន្ធនាគារ PJ ជាការលើកឡើងដោយមិនមានការទទួលខុសត្រូវ ពីព្រោះកិច្ចព្រមព្រៀងនេះធ្វើឡើងនៅចំពោះមុខភរិយារបស់សហចុងចម្លើយទាំងបីនាក់ និងសហចុងចម្លើយទៀត ហើយសហចុងចម្លើយទាំងបីនាក់ក៏បានព្រមព្រៀងផ្តិតមេដៃទទួលស្គាល់ហើយ និងមានការដឹងលឺពីសំណាក់លោកមេធាវីគូភាគីទាំងពីរនេះ ដែលបង្ហាញពីឆន្ទៈច្បាស់លាស់នៃកិច្ចព្រមព្រៀងនេះ ។ ខ្លួនសូមប្រានចោលការលើកឡើងរបស់មេធាវីចុងចម្លើយដែលលើកឡើងថា កូនក្តីរបស់ខ្លួនអះអាងថា ធ្វើកិច្ចព្រមព្រៀងនេះ គឺដើម្បីឲ្យចុងចម្លើយបានរួចពីពន្ធនាគារ និងដកពាក្យបណ្តឹង ការលើកឡើងនេះ គឺមិនមានភស្តុតាង និងសាក្សីច្បាស់លាស់ទេ ។

កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ លោកមេធាវីតំណាងដោយអណត្តិឲ្យចុងចម្លើយបានលើកឡើងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ថាកូនក្តីរបស់គាត់(ស្ទួស សិរីរ័ត្ន) តែម្នាក់គត់

ដែលបានបង់ប្រាក់ និងផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិខ្លះរបស់គាត់ ([redacted] សិរីវ័ត្ន) ចំនួន ១៩៥.០០០(ដប់ប្រាំបួនម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ឲ្យមកដើមចោទឈ្មោះ [redacted] ពីឌិច រួចទៅហើយ មិនគប្បីឲ្យឈ្មោះ [redacted] សិរីវ័ត្ន ទទួលខុសត្រូវលើប្រាក់សំណងអ្វីទៀតទេ ។ ប៉ុន្តែបើស្តាប់ចម្លើយសារភាពរបស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ស្រស់ បានសារភាពថាឈ្មោះ [redacted] សិរីវ័ត្ន ជាអ្នកចាត់ចែង និងជាមេចំណែកទាំងអស់ ហើយទទួលបានចំណែកច្រើនជាងគេ គឺឈ្មោះ [redacted] សិរីវ័ត្ន គឺជាមេចំណែក ឯពួកគេទាំងពីរនាក់ ([redacted] ស្រស់ និង [redacted] ម៉ៅ) គឺទទួលបានបន្តិចបន្តួចទេ ដោយមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌នៅនាយកដ្ឋាននគរបាលព្រហ្មទណ្ឌនៃក្រសួងមហាផ្ទៃ ។

**គ.២. អង្គហេតុដែលអះអាងដោយចុងចម្លើយៈ**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្លួនសុំបដិសេធនូវការប្តឹងទាមទារប្រាក់ចំនួនចំនួន ៤០៥:០០០ (សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ពីកូនក្តីខ្លួនជាចុងចម្លើយឈ្មោះ [redacted] សិរីវ័ត្ន និងអ្នកពាក់ព័ន្ធឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ត្រង់ចំណុចទី១ ទី២ ទី៣ ទី៤ និងទី៥ ក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញសាលក្រម ព្រោះកូនក្តីខ្លួនឈ្មោះ [redacted] សិរីវ័ត្ន ព្រមទាំងអ្នកពាក់ព័ន្ធឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ មិនដែលបានខ្ចីប្រាក់ពីឈ្មោះ [redacted] ពីឌិច ទេ ព្រោះដើមឡើយកាលពីឆ្នាំ២០១៦ ឈ្មោះ [redacted] សិរីវ័ត្ន និងមិត្តភក្តិឈ្មោះ [redacted] ស្រស់ បានទៅផឹកកាហ្វេនៅហាង គីរីរម្យ២ រាជធានីភ្នំពេញ ជាមួយបងធម៌ ក៏បានជួបជាមួយឈ្មោះ [redacted] ពីឌិច ដែលស្គាល់គ្នាជាមួយបងធម៌របស់ឈ្មោះ [redacted] សិរីវ័ត្ន ហើយបានអង្គុយក្នុងហាងកាហ្វេជុំគ្នា ។ នៅពេលជុំគ្នានោះឈ្មោះ [redacted] ស្រស់ បានផ្តើមនិយាយពីរឿងថ្មចម្លែកដែលស៊ីដែក ពេលនោះដើមចោទឈ្មោះ [redacted] ពីឌិច ក៏មានចំណាប់អារម្មណ៍ហើយក៏បានហុចនាមប័ណ្ណរបស់គាត់ឲ្យទៅឈ្មោះ [redacted] ស្រស់ មួយសន្លឹកឲ្យទៅឈ្មោះ [redacted] សិរីវ័ត្ន ។ បន្ទាប់មកក្រោយពីឈ្មោះ [redacted] សិរីវ័ត្ន និងឈ្មោះ [redacted] ស្រស់ ចាកចេញពីហាងគីរីរម្យ២ ឈ្មោះ [redacted] សិរីវ័ត្ន និងឈ្មោះ [redacted] ស្រស់ ក៏បានជួបជនជាតិវៀតណាម ២នាក់ ហើយជនទាំងពីរនាក់នោះក៏បាននិយាយថា ពួកគេមានថ្មស៊ីដែក ឮដូច្នេះដោយបានដឹងថា ឈ្មោះ [redacted] ពីឌិច មានចំណាប់អារម្មណ៍ចង់ទិញថ្មស៊ីដែកនោះ ឈ្មោះ [redacted] សិរីវ័ត្ន និងឈ្មោះ [redacted] ស្រស់ ក៏បានទូរស័ព្ទទៅឈ្មោះ [redacted] ពីឌិច ប្រាប់ថាមានជនជាតិវៀតណាម ០២នាក់ មានថ្មស៊ីដែក គេចង់លក់តម្លៃ ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ពេលនិយាយទូរស័ព្ទនោះ ឈ្មោះ [redacted] ពីឌិច ក៏ឲ្យឈ្មោះ [redacted] សិរីវ័ត្ននិងឈ្មោះ [redacted] ស្រស់ នាំជនជាតិវៀតណាមនោះយកថ្មទៅឲ្យគាត់សាកមើលនៅត្រង់ចំណុចដើមពោធិ៍វត្តស្លែង ។ បន្ទាប់មកឈ្មោះ [redacted] សិរីវ័ត្ន និងឈ្មោះ [redacted] ស្រស់ ក៏បាននាំជនជាតិវៀតណាមទាំងពីរនាក់នោះទៅជួបឈ្មោះ [redacted] ពីឌិច តាមការប្រាប់ ហើយក៏បានជួបឈ្មោះ អ៊ុន ពីឌិច នៅចំណុចដើមពោធិ៍វត្តស្លែងនៅម៉ោង ៩ព្រឹក ។ ពេលឈ្មោះ [redacted] ពីឌិច បានជួបជនជាតិវៀតណាមទាំងពីរនាក់ហើយ ឈ្មោះ [redacted] ពីឌិច ក៏បានយកដែកថ្នាំងអំពៅសាកជាមួយថ្មស៊ីដែកនោះដោយខ្លួនឯង ហើយគាត់បានយកដែកនោះមកកាច់ ដែកនោះក៏ផុយដូចដីស បន្ទាប់ពីសាកហើយ ឈ្មោះ [redacted] ពីឌិច ក៏មានការជឿជាក់ ហើយបានប្រគល់ប្រាក់ចំនួន **៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក** ឲ្យទៅជនជាតិវៀតតណាមទាំងពីរនាក់នោះ រួចឈ្មោះ [redacted] ពីឌិច ក៏យកដុំថ្មនោះដាក់ក្នុងរថយន្តរបស់គាត់ ហើយបើករថយន្តចេញបាត់ទៅ ។ លុះដល់ម៉ោង ២រសៀល ឈ្មោះ [redacted] ពីឌិច បានទូរស័ព្ទមកប្រាប់ឈ្មោះ [redacted] សិរីវ័ត្ន និងឈ្មោះ [redacted] ស្រស់ ថាជារបស់ពិតហើយ ប្រើឯកទៅចាំគាត់ធ្វើសណ្ឋាគារឲ្យម្នាក់០១ជុងឲ្យ ។ ស្រាប់តែមកដល់វេលាម៉ោង ៦ និង ៣០នាទី ឈ្មោះ [redacted] ពីឌិច បានទូរស័ព្ទមកឈ្មោះ [redacted] សិរីវ័ត្ន និងឈ្មោះ [redacted] ស្រស់ ម្តងទៀតប្រាប់ថាជារបស់ក្លែងក្លាយ ឲ្យឈ្មោះ [redacted] សិរីវ័ត្ន និងឈ្មោះ [redacted]

ស្រស់ ជួយតាមរកជនជាតិវៀតណាមទាំងពីរនាក់ឲ្យឃើញចាំគាត់វៃលុយឲ្យធ្វើសោហ៊ុយ ចាយវាយ ហើយបើជួបជនជាតិវៀតណាមទាំងពីរនាក់ ឲ្យជួយប្រាប់ជនជាតិវៀតណាមនោះឲ្យយករបស់ពិតមកឲ្យគាត់វិញ ព្រោះគាត់ទូរស័ព្ទបានជួបជនជាតិវៀតណាមទាំងពីរនាក់នោះរហូត ។ បន្ទាប់ពីឈ្មោះ [redacted] ពីឌិច បានប្រាប់ឲ្យឈ្មោះ [redacted] សិរីរ័ត្ន និងឈ្មោះ [redacted] ស្រស់ ឲ្យជួយតាមរកជនជាតិវៀតណាមនោះ ឈ្មោះ [redacted] ពីឌិច តែងតែវៃលុយតាមវីងឲ្យទៅឈ្មោះ [redacted] សិរីរ័ត្ន និងឈ្មោះ [redacted] ស្រស់ ធ្វើសោហ៊ុយ និងចាយវាយរហូត ដោយវៃម្តងៗចាប់ពី ១.០០០(មួយពាន់)ដុល្លារអាមេរិក ២.០០០(ពីរពាន់) ដុល្លារអាមេរិក ៣.០០០ (បីពាន់)ដុល្លារអាមេរិក ៥.០០០(ប្រាំពាន់) ដុល្លារអាមេរិក ឬ ៧.០០០(ប្រាំពីរពាន់)ដុល្លារអាមេរិក រហូតដល់ ១៥.០០០(មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ក៏មាន ដោយឈ្មោះ [redacted] ពីឌិច វៃប្រាក់ឲ្យឈ្មោះ [redacted] សិរីរ័ត្ន និងឈ្មោះ [redacted] ស្រស់ អស់រយៈពេលប្រហែល ០២ឆ្នាំ ក្រោយមកក៏មានឈ្មោះ [redacted] ម៉ៅ ជាមិត្តភក្តិរបស់ឈ្មោះ [redacted] សិរីរ័ត្ន និងឈ្មោះ [redacted] ស្រស់ បានមកសហការដើររកជនជាតិវៀតណាមនោះដែរ ហើយនៅពេលឈ្មោះ [redacted] ពីឌិច បានស្គាល់ឈ្មោះ [redacted] ម៉ៅ ឈ្មោះ [redacted] ពីឌិច ក៏បានវៃប្រាក់ឲ្យធ្វើសោហ៊ុយចាយវាយតាមរយៈឈ្មោះ [redacted] ម៉ៅ ផងដែរ ។ ក្រោយមកនៅចុងឆ្នាំ២០១៨ ឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ទៅស្វែងរកជនជាតិវៀតណាមទាំងពីរនាក់ ដល់ស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ ហើយដេកផ្ទះសំណាក់នៅទីនោះ ស្រាប់តែឃើញឈ្មោះ [redacted] ពីឌិច នាំសមត្ថកិច្ចនគរបាលទៅចាប់ខ្លួនឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ នាំយកមកក្រសួងមហាផ្ទៃ ទើបឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ដឹងថាឈ្មោះ [redacted] ពីឌិច បានប្តឹងពីឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ចូលក្រសួងមហាផ្ទៃពីបទឆបោកប្រាក់របស់គាត់ចំនួន ២.៥០០.០០០ (ពីរលានប្រាំសែន)ដុល្លារអាមេរិក និងពីបទ គម្រាមកំហែងថានឹងសម្លាប់ តាមពិតឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ មិនបានឆបោកប្រាក់ និងមិនបានគម្រាមកំហែងថានឹងសម្លាប់អ្វីនោះទេ ហើយទោះបីជាអ្នកទាំង០៣នាក់ខំប្រកែកដោះសារយ៉ាងណាក៏ដោយ ក៏ឈ្មោះ [redacted] ពីឌិច មិនព្រមអនុគ្រោះ ហើយសមត្ថកិច្ចនគរបាលក្រសួងមហាផ្ទៃមិនព្រមដោះលែងដែរ ហើយសមត្ថកិច្ចនគរបាលក្រសួងមហាផ្ទៃបានកសាងសំណុំរឿងបញ្ជូនខ្លួនឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ មកសាលាដំបូងរាជធានីភ្នំពេញ និងក៏ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ សម្រេចឃុំខ្លួនឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ បណ្ដោះអាសន្ននៅពន្ធនាគាររាជធានីភ្នំពេញ ។ នៅចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ ឈ្មោះ [redacted] ពីឌិច នៅតែប្តឹងទាមទារប្រាក់ពីឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ចំនួន ២.៥០០.០០០(ពីរលានប្រាំសែន)ដុល្លារអាមេរិក និងទាមទារប្រាក់ជម្ងឺចិត្តចំនួន ៥០០.០០០(ហាសិបម៉ឺន)ដុល្លារអាមេរិក ប៉ុន្តែនៅចំពោះមុខចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ឈ្មោះ [redacted] សិរីរ័ត្ន បានទាមទារឲ្យឈ្មោះ [redacted] ពីឌិច បង្ហាញភស្តុតាងឲ្យឃើញថា ពួកខ្លួនពិតជាបានឆបោកប្រាក់ និងគម្រាមកំហែងថានឹងសម្លាប់ បើមានភស្តុតាង ឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ សុខចិត្តទទួលទោស និងសងប្រាក់ដែលថាឆបោកនោះទាំងអស់ ប៉ុន្តែនៅពេលដែលតុលាការបង្គាប់ឲ្យឈ្មោះ [redacted] ពីឌិច ដាក់ភស្តុតាងពាក់ព័ន្ធនឹងបទចោទប្រកាន់ទាំងអស់ ឈ្មោះ [redacted] ពីឌិច ដាក់បានត្រឹមតែក្រដាសវិក័យបត្រវីង ដែលមានទឹកប្រាក់សរុបចំនួន ៣៤០.០០០ (សាមសិបបួនម៉ឺន) ដុល្លារអាមេរិក តែប៉ុណ្ណោះ ពុំមានភស្តុតាងអ្វីផ្សេងទៀតទេ ។ ដោយមូលហេតុនៃការរកភស្តុតាងស្តីពីប្រាក់មិនបានដល់ចំនួន ២.៥០០.០០០(ពីរលានប្រាំសែន)ដុល្លារអាមេរិក ដូចការទាមទារ បែរជាឈ្មោះ [redacted] ពីឌិច ឲ្យមេធាវីរបស់គាត់ និងមេធាវីរបស់ឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ រកវិធីចរចារ និងធ្វើកិច្ចព្រមព្រៀងដើម្បីទទួលបានប្រាក់ពីឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ខ្លះហើយសុខចិត្តធ្វើពាក្យដកពាក្យបណ្តឹងពីក្នុងសំណុំរឿងព្រហ្ម

ទណ្ឌលេខ ៧៤៥០ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ និងជួយសម្របសម្រួលខាងតុលាការឲ្យឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ បាននៅក្រៅឃុំបណ្ដោះអាសន្នសិន ដើម្បីឲ្យឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ រកប្រាក់មកសងវិញឲ្យគ្រប់ចំនួន ដូចមានចែងក្នុងប្រការ៥ នៃកិច្ចព្រមព្រៀងបញ្ចប់វិវាទ ដែលដើមចោទបានដាក់ជាភស្តុតាងជាមួយពាក្យបណ្ដឹង ហើយនៅក្នុងកិច្ចព្រមព្រៀងនេះទៀតសោត ភាគី [redacted] ពីឱច បានតម្រូវឲ្យឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ឯកភាពលើទឹកប្រាក់ជាក់ស្ដែងចំនួន ៦០០.០០០(ហុកសិបម៉ឺន)ដុល្លារអាមេរិក ជាបណ្ដោះអាសន្នសិន ដូចមានចែងក្នុងប្រការ១ នៃកិច្ចព្រមព្រៀងបញ្ចប់វិវាទ និងឲ្យឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ សងប្រាក់ និងផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិខ្លះទៅឲ្យឈ្មោះ [redacted] ពីឱច ក្នុងនេះមានៈ ឲ្យប្រគល់ប្រាក់ចំនួន ៨០.០០០ (ប្រាំបីម៉ឺន)ដុល្លារអាមេរិក ជាបណ្ដោះអាសន្នសិន នៅថ្ងៃចុះកិច្ចព្រមព្រៀង, ប្រគល់អចលនវត្ថុដែលមានទីតាំងស្ថិតនៅភូមិចិនដាំម្លូ ឃុំរាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដើម្បីកាត់កងប្រាក់ស្មើនឹង ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក, ប្រគល់អចលនវត្ថុដីទំហំ ២០ម៉ែត្រ គុណនឹង ២០ម៉ែត្រ ដែលមានទីតាំងស្ថិតនៅភូមិឈូកស ឃុំព្រះស្រែ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដើម្បីកាត់កងប្រាក់ស្មើនឹងចំនួន ២០.០០០(ពីរម៉ឺន)ដុល្លារអាមេរិក ប្រគល់រថយន្តម៉ាកឡង់គ្រីស័រពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ ២BD-៦៩៦៩ ដើម្បីកាត់កងប្រាក់ស្មើនឹងចំនួន ៧០.០០០(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ។ សរុបស្មើនឹងទឹកប្រាក់ចំនួន ១៩០.០០០(ដប់ប្រាំបួនម៉ឺន)ដុល្លារអាមេរិក ដូចមានចែងក្នុងប្រការ២ នៃកិច្ចព្រមព្រៀងបញ្ចប់វិវាទ ។ ក្រៅពីការសងប្រាក់ និងផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិខាងលើនេះ ឈ្មោះ [redacted] ពីឱច បានតម្រូវឲ្យឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ សងប្រាក់ប្រចាំខែចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក ក្នុង០១ខែ ថែមទៀត ដូចមានចែងក្នុងប្រការ៣ នៃកិច្ចព្រមព្រៀង ហើយក្នុងការអនុវត្តប្រការ៣ នៃកិច្ចព្រមព្រៀងនេះឈ្មោះ សួស សិរីរ័ត្ន បានសងប្រាក់ប្រចាំខែឲ្យដើមចោទឈ្មោះ [redacted] ពីឱច រួចហើយដែរ ។ ចំពោះកិច្ចព្រមព្រៀងខាងលើនេះជាកិច្ចព្រមព្រៀងដែលមានវិការៈ ព្រោះជាកិច្ចព្រមព្រៀងដែលត្រូវបានបង្កើតឡើងក្នុងកាលៈទេសៈមួយដែលឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ កំពុងជាប់ឃុំខ្លួននៅពន្ធនាគារPJ ហើយដើមចោទឈ្មោះ [redacted] ពីឱច អះអាងថានឹងដកពាក្យបណ្ដឹង និងជួយសម្របសម្រួលតុលាការឲ្យឈ្មោះ [redacted] សិរីរ័ត្ន, ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ នៅក្រៅឃុំបណ្ដោះអាសន្នផងនោះ ទើបឈ្មោះ [redacted] សិរីរ័ត្ន, ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ចេះតែព្រមចុះកិច្ចព្រមព្រៀងទាំងបង្ខំចិត្តក្រៅពីឆន្ទៈរបស់ខ្លួន ហើយបើតាមច្បាប់កិច្ចព្រមព្រៀងដែលកើតឡើងក្នុងពេលដែលភាគីម្ខាងស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបានតាមមាត្រា១៤ នៃក្រមរដ្ឋប្បវេណី ។ ប៉ុន្តែទោះជាកិច្ចព្រមព្រៀងនេះអាចលុបបានតាមច្បាប់ក៏ដោយក៏ឈ្មោះ [redacted] សិរីរ័ត្ន តែម្នាក់ឯងបានសងប្រាក់ និងផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិខ្លះរបស់ខ្លួនដែលមានទឹកប្រាក់ស្មើនឹងចំនួន ១៩៥.០០០(ដប់ប្រាំបួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ឲ្យទៅដើមចោទឈ្មោះ [redacted] ពីឱច រួចទៅហើយ មិនគប្បីឲ្យឈ្មោះ [redacted] សិរីរ័ត្ន ទទួលខុសត្រូវលើប្រាក់សំណងអ្វីតទៅទៀតទេ ។ ម្យ៉ាងទៀតប្រាក់ដែលដើមចោទមានភស្តុតាងពិតប្រាកដពាក់ព័ន្ធនឹងឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ មានតែក្រដាសវិក័យបត្រវីងមានទឹកប្រាក់សរុបចំនួន ៣៤០.០០០(សាមសិបបួនម៉ឺន)ដុល្លារអាមេរិក តែប៉ុណ្ណោះ មិនត្រូវបង្កើតកិច្ចព្រមព្រៀងចាប់បង្ខំឲ្យឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ទទួលខុសត្រូវលើទឹកប្រាក់តាមកិច្ចព្រមព្រៀងដែលចែងថា ឯកភាពលើទឹកប្រាក់ជាក់ស្ដែងចំនួន ៦០០.០០០(ហុកសិបម៉ឺន) ដុល្លារអាមេរិក ជាបណ្ដោះអាសន្នសិននោះទេ ហើយក៏មិនគប្បីយកកិច្ចព្រមព្រៀងបញ្ចប់វិវាទនេះមកធ្វើជាមូលដ្ឋានភស្តុតាងក្នុងការប្ដឹងទាមទារប្រាក់ដែលនៅសល់ចំនួន ៤០៥.០០០(សែសិបម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ពីឈ្មោះ [redacted]



Scanned with CamScanner

សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ នោះដែរ គប្បីប្តឹងទាមទារតែទៅលើទឹកប្រាក់ក្នុងវិក័យបត្រវែងចំនួន ៣៤០.០០០(សាមសិបបួនម៉ឺន)ដុល្លារអាមេរិក តែប៉ុណ្ណោះ ទើបមានភស្តុតាងជាមូលដ្ឋានប្រសើរជាង ។ ហេតុនេះ ទាក់ទងនឹងការប្តឹងទាមទារប្រាក់ចំនួន៤០៥.០០០(សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក របស់ដើមចោទឈ្មោះ [redacted] ពីឱច សូមតុលាការច្រានចោល ព្រោះមិនគប្បីឲ្យឈ្មោះ [redacted] សិរីរ័ត្ន ទទួលខុសត្រូវសងប្រាក់អ្វីឲ្យដើមចោទតទៅទៀតទេ ។ ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ៧៤៥០ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ បើកសវនាការជំនុំជម្រះចេញសាលក្រមលេខ ៣៦១ (ខ១) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ សម្រេចផ្តន្ទាទោសឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ១ឆ្នាំ ៦ខែ ពីបទ ឆបោក និងសម្រេចឲ្យឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ រួចផុតពីបទចោទ ពីបទ គម្រាមកំហែងថានឹងសម្លាប់ ។ ទុកសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពីឱច ទាមទារសំណងនាពេលក្រោយ ។ សាលក្រមនេះត្រូវបានឈ្មោះ [redacted] សិរីរ័ត្ន ប្តឹងឧទ្ធរណ៍តាមពាក្យបណ្តឹង ចុះថ្ងៃទីពុធ ០៤កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ពស២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ហើយក្រោយពីចេញសាលក្រម និងក្រោយពីបានប្តឹងឧទ្ធរណ៍លើសាលក្រម ឈ្មោះ [redacted] សិរីរ័ត្ន ក៏បញ្ឈប់ការសងប្រាក់ប្រចាំខែឲ្យឈ្មោះ [redacted] ពីឱច ព្រោះរង់ចាំសាលដីកាសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ។ ចំណែកឯឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ បច្ចុប្បន្នមិនដឹងថាទៅរស់នៅទីណាទេ ។ ចំពោះឈ្មោះ [redacted] ពីឱច ក្រោយពីសាលាដំបូងរាជធានីភ្នំពេញចេញសាលក្រមលេខ ៣៦១(ខ១) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ រួចហើយ ឈ្មោះនេះបានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ពីបទ ឆបោក និងគម្រាមថានឹងសម្លាប់ ម្តងទៀត ដែលមានសំណុំរឿងលេខ ៥០៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ តែសំណុំរឿងពាក់ព័ន្ធនឹងបណ្តឹងជាលើកទី២នេះ ត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សម្រេចតម្កល់រឿងទុកឥតចាត់ការ តាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ១៦៣២ អ.យ.ឈ ចុះថ្ងៃចន្ទ ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ។ បន្ទាប់ពីប្តឹងរឿងព្រហ្មទណ្ឌម្តងហើយម្តងទៀតនៅសាលាដំបូងរាជធានីភ្នំពេញ ពុំទទួលបានប្រាក់សំណងអ្វីនោះ ឈ្មោះ [redacted] ពីឱច នៅតែព្យាយាមចង់បានប្រាក់ និងទ្រព្យសម្បត្តិរបស់កូនក្តីខ្លួនឈ្មោះ [redacted] សិរីរ័ត្ន និងអ្នកពាក់ព័ន្ធឈ្មោះ [redacted] ស្រស់ ឈ្មោះ [redacted] ម៉ៅ ដដែលនោះ ទើបឈ្មោះ [redacted] ពីឱច បែរជាមកប្តឹងរឿងរដ្ឋប្បវេណីចូលសាលាដំបូងខេត្តកំពង់ស្ពឺវិញ ដោយប្តឹងទាមទារប្រាក់ចំនួន ៤០៥.០០០(សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ពីកូនក្តីខ្លួនឈ្មោះ [redacted] សិរីរ័ត្ន និងអ្នកពាក់ព័ន្ធឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ដោយសំអាងទៅលើកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ដែលធ្វើឡើងដោយផ្ទុយពីច្បាប់ទៅវិញ ។ ហេតុនេះហើយបានជាខ្លួនសុំឲ្យលោកចៅក្រមសម្រេចច្រានចោលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted]ន ពីឱច ហើយចំពោះការទាមទារនេះ ខ្លួននឹងដាក់តបនៅពេលក្រោយ ។ អាស្រ័យហេតុនេះ សូមលោកចៅក្រមមេត្តាពិនិត្យសម្រេចតាមច្បាប់ ។ ចំពោះប្រពន្ធរបស់ឈ្មោះ [redacted] សិរីរ័ត្ន ឈ្មោះ [redacted] ស្រស់ និងឈ្មោះ [redacted] ម៉ៅ ដែលបានផ្តិតមេដៃលើកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ក៏ធ្វើឡើងក្នុងគោលបំណងឲ្យប្តីបានរួចពីពន្ធនាគារផងដែរ ព្រោះដើមចោទបានអះអាងថា នឹងដកពាក្យបណ្តឹង និងជួយសម្របសម្រួលជាមួយតុលាការឲ្យឈ្មោះ [redacted] ស្រស់, ឈ្មោះ [redacted] សិរីរ័ត្ន និងឈ្មោះ [redacted] ម៉ៅ រួចពីពន្ធនាគារ ហើយប្រពន្ធរបស់អ្នកទាំងបីនេះ ក៏មិនបានយល់ដឹងអំពីផលវិបាកគតិយុត្តទៅថ្ងៃមុខដែរ ។

## II. ការពិនិត្យភស្តុតាង



Scanned with CamScanner

**១. ភស្តុតាងជាឯកសាររបស់ដើមចោទ**

- កិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ចំនួន ០១ច្បាប់ ។

- កំណត់ហេតុស្តាប់ចម្លើយឈ្មោះ [redacted] **ម៉ៅ** នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ចំនួន ០១ច្បាប់ ។

- កំណត់ហេតុស្តាប់ចម្លើយឈ្មោះ [redacted] **ស្រស់** នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ចំនួន ០១ច្បាប់ ។

- លិខិតប្រគល់ ទទួលប្រាក់ប្រចាំខែ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ចំនួន ០១ច្បាប់ ។

- លិខិតបញ្ជាក់ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ របស់មេភូមិវិហារខ្ពស់ ចំនួន ០១ច្បាប់ ។

**២. ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

- វិក័យបត្រវេរប្រាក់តាមវីងចំនួន ៧៣ច្បាប់ ដែលមានវិក័យបត្រវីងចំនួន ៣៥៦សន្លឹក ។

## <u>សំអាងហេតុ</u>

ឆ្លងតាមនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ឃើញថា ៖

**១. តើកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ រវាងដើមចោទ និងសហចុងចម្លើយធ្វើឡើងដោយមានវិការៈ ដែរឬទេ?**

-ចុងចម្លើយបានអះអាងថា កិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ជាកិច្ចព្រមព្រៀងដែលមានវិការៈ ដោយសារតែកិច្ចព្រមព្រៀងនេះត្រូវបានបង្កើតឡើងក្នុងកាលៈទេសៈមួយដែលភាគីម្ខាងស្ថិតនៅក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់របស់ខ្លួន ។ តាមការពិនិត្យលើកិច្ចព្រមព្រៀងនេះ ឃើញថាកិច្ចព្រមព្រៀងនេះធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានស្នាមមេដៃរបស់សហចុងចម្លើយ សាក្សី និងមានចុះហត្ថលេខាដោយមេធាវីរបស់ខ្លួនទៀតផង ។ ហេតុនេះតុលាការមិនទទួលស្គាល់អង្គហេតុ ដែលអះអាងដោយចុងចម្លើយនេះទេ ។

**២. ការទាមទារឲ្យសហចុងចម្លើយឈ្មោះ [redacted] សិរីរ័ត្ន, ឈ្មោះ [redacted]** ស្រស់ **និងឈ្មោះ [redacted]** ម៉ៅ **សងប្រាក់ដែលនៅជំពាក់ចំនួន ៤០៥.០០០ (សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច**

- តាមភស្តុតាងជាឯកសារ (កិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩) និងការទទួលស្គាល់របស់គូភាគី ធ្វើឲ្យតុលាការទទួលស្គាល់ថា មានអង្គហេតុដែលគូភាគី បានចុះកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ដោយឯកភាពគ្នាលើទឹកប្រាក់ជាក់ស្តែងចំនួន **៦០០.០០០ (ហុកសិបម៉ឺន) ដុល្លារអាមេរិក** ។

- យោងតាមប្រការ២ នៃកិច្ចព្រមព្រៀងបញ្ចប់វិវាទ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ដែលមានខ្លឹមសារចុងចម្លើយយល់ព្រមសងប្រាក់ និងផ្ទេរកម្មសិទ្ធិលើទ្រព្យខ្លះទៅឲ្យដើមចោទ និង តាមការទទួលស្គាល់របស់គូភាគី អំពីចំនួននៃទឹកប្រាក់សរុបដែលចុងចម្លើយបានបង់ទៅឲ្យដើមចោទនៃរឿងក្តីនេះ ។ ធ្វើឲ្យតុលាការទទួលស្គាល់ថា មានអង្គហេតុដែលដើមចោទ ទទួលបានប្រាក់ចំនួន **១៩៥.០០០ (ដប់ប្រាំបួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** ពីចុងចម្លើយឈ្មោះ [redacted] **សិរីរ័ត្ន** គិតត្រឹមថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។

**៣. តើការទាមទារសំណងជម្ងឺចិត្ត និងថ្លៃសេវាផ្សេងៗចំនួន ១០០.០០០(ដប់ម៉ឺនដុល្លារ) អាមេរិក មានមូលហេតុត្រឹមត្រូវតាមច្បាប់ដែរឬទេ ?**

-ដើមចោទបានទាមទារឱ្យចុងចម្លើយសងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្នែកច្បាប់ចំនួន **១០០.០០០ (ដប់ម៉ឺន)ដុល្លារអាមេរិក** ដោយសំអាងថា ការមិនអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងរបស់សហចុងចម្លើយធ្វើឲ្យរូបគេខាតបង់ពេលវេលា និងចំណាយលើសេវាផ្នែកច្បាប់ ។ ចំណុចនេះតុលាការនឹងពិចារណាឲ្យចុងចម្លើយសងទៅដើមចោទ ដោយផ្អែកតាមមាត្រា ៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា ៤០០ និងមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី កំហុសរបស់ចុងចម្លើយ ការខូចខាត និងផលប៉ះពាល់ជាក់ស្តែងដែលដើមចោទទទួលរង ។

**៤. តើការទាមទារឲ្យសហចុងចម្លើយសងនូវការប្រាក់ ចំនួន ០២%(ពីរភាគរយ) ក្នុងមួយខែ នៃប្រាក់ដែលនៅជំពាក់ចំនួន ៤០៥.០០០ (សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក មកឲ្យដើមចោទឈ្មោះ សួស សិរីវ័ត្ន គិតចាប់ពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមអស់ មានមូលហេតុត្រឹមត្រូវតាមច្បាប់ ដែរឬទេ ?**

- យោងតាមកិច្ចព្រមព្រៀងបញ្ចប់វិវាទ ត្រង់ប្រការ៣ ដែលមានខ្លឹមសារ ប្រសិនបើសហចុងចម្លើយមិនគោរពកាតព្វកិច្ចសងប្រាក់ឲ្យទៅដើមចោទ នោះសហចុងចម្លើយត្រូវបង់ប្រាក់ពិន័យក្នុងមួយខែស្មើនឹង ២% (ពីរភាគរយ) នៃចំនួនទឹកប្រាក់ដែលនៅសល់ពីការជំពាក់ ។ នេះជាចំនួនប្រាក់ពិន័យ ក្នុងករណីសហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចដែលកំណត់ក្នុងកិច្ចព្រមព្រៀង មិនមែនជាអត្រាការប្រាក់នោះទេ ហើយការទាមទារប្រាក់នៃរឿងក្តីនេះ គឺការទាមទារដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយ មិនមែនជាកិច្ចសន្យាខ្ចីប្រាក់ ដោយភ្ជាប់នឹងការប្រាក់នោះទេ ដូចនេះតុលាការមិនទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទនេះទេ ។ គប្បីតុលាការសម្រេចច្រានចោល ។

**៥. តើការសុំអនុវត្តសាលក្រមនេះជាបណ្តោះអាសន្នត្រង់ចំណុចទី១ នៃការទាមទារ មានមូលហេតុតាមផ្លូវច្បាប់ ដែរឬទេ ?**

- ដើមចោទបានទាមទារសុំប្រកាសអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ នៃខ្លឹមសារនៃសាលក្រមដែលរូបគេទាមទារនោះ ។ ការទាមទាររបស់ដើមចោទ គឺជាការទាមទារប្រាក់ (ការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ) មានភស្តុតាងជាលាយលក្ខណ៍អក្សរ គឺកិច្ចព្រមព្រៀងបញ្ចប់វិវាទ ហើយតុលាការយល់ឃើញថាមានភាពចាំបាច់ គប្បីប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នតែលើការទាមទារប្រាក់ដើមប៉ុណ្ណោះ តាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៦.** យោងកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨ របស់ចុងចម្លើយឈ្មោះ [redacted] **ម៉ៅ** និងឈ្មោះ [redacted] **ស្រស់** របស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ភាគីចុងចម្លើយបានឆ្លើយសារភាព និងផ្តិតមេដៃទទួលស្គាល់ថា ខ្លួនពិតជាបានឆបោកប្រាក់ពីភាគីដើមចោទមែន ។

**៧.** តុលាការបានបញ្ជូនពត៌មាន និងឯកសារពាក់ព័ន្ធទៅសហចុងចម្លើយឈ្មោះ [redacted] **ស្រស់** និងឈ្មោះ [redacted] **ម៉ៅ** ប៉ុន្តែសហចុងចម្លើយអវត្តមាននៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយក៏ពុំមានសញ្ញាណណាមួយដែលបង្ហាញឲ្យឃើញថា សហចុងចម្លើយបានធ្វើវិវាទកម្មលើសេចក្តីថ្លែងការណ៍របស់ដើមចោទដែរ ដូច្នេះចាត់ទុកថា សហចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ។ យោងតាមមាត្រា ២០១



Scanned with CamScanner

នៃក្រមនីតិវិធីរដ្ឋប្បវេណី បើចុងចម្លើយ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថាចុងចម្លើយបានសារភាព តាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទង និងអង្គហេតុ ។

៨. រាល់សំអាងហេតុដូចបានរៀងរាប់ខាងលើ ពិតជាមានអត្ថិភាពនៃអង្គហេតុដែលជាមូលដ្ឋាននៃការទាមទាររបស់ដើមចោទ ដែលគប្បីតុលាការសម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ ។

**៩. បន្ទុកនៃប្រាក់ប្រដាប់ក្តី**

នៅក្នុង "រឿងក្តីប្តឹងទាមទារប្រាក់" នេះ សហចុងចម្លើយចាញ់ក្តីដើមចោទ ហេតុនេះយោងតាមបញ្ញត្តិមាត្រា ៦៤-១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទុកនៃប្រាក់ប្រដាប់ក្តី ត្រូវឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកទាំងស្រុង ។

## សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើមនៅជំពាក់ចំនួន **៤០៥.០០០ (សែសិបម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** ឲ្យទៅដើមចោទ ។

២. បង្គាប់អោយសហចុងចម្លើយបង់សំណងជម្ងឺចិត្ត លើការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន **១២០.០០០.០០០៛ (មួយរយម្ភៃលាន) រៀល** ឲ្យទៅដើមចោទ ។ ការទាមទារលើសពីនេះត្រូវប្រានចោល ។

៣. ប្រានចោលការទាមទារចំណុចទី៣ នៃពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] **ពីនិច** ។

៤. សាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១ ។

៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីសហចុងចម្លើយ ។

-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ៥រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ គិតចាប់ពីពេលដែលភាគីបានទទួលអនុសារសាលក្រមនេះតទៅ ។

**ចៅក្រម**

ហត្ថលេខា និងត្រា : [redacted]

.................................................................................................................................

អនុសារសាលក្រមនេះមានអានុភាពដូចមូលសាលក្រមដែរ

ថ្ងៃព្រហស្បតិ៍ ០៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកំពង់ស្ពឺ, ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]